# ឋានន្តរៈ ព្រះអម្ចាស់

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

ឋានន្តរជា «ព្រះអម្ចាស់» គឺជាឋានន្តរទីពីររបស់ព្រះយេស៊ូវ ដែលព្រះគម្ពីរសញ្ញាថ្មីបានប្រើច្រើនបំផុត។ គោលជំនឿរបស់ពួកជំនុំដំបូងគឺ «ព្រះយេស៊ូវគឺជាព្រះអម្ចាស់»។

*ការប្រើពាក្យ «ព្រះអម្ចាស់» ខុសៗគ្នានៅក្នុងព្រះគម្ពីរសញ្ញាថ្មី។*

ឋានន្តរជា «ព្រះអម្ចាស់» ដែលមកពីភាសាក្រិក (*kurios)* មានអត្ថន័យបីនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។

ទីមួយ ពាក្យនេះមានការប្រើជាទូទៅ ដែលជាការគួរសមសំរាប់ហៅមនុស្សដទៃ។ នៅក្នុងកណ្ដដំណឹងល្អ អ្នកដទៃហៅព្រះយេស៊ូវថា «ព្រះអម្ចាស់» នៅពេលពួកគេនិយាយទៅកាន់ព្រះអង្គ។ នេះមិនមានន័យថា ពួកគេបានទទួលស្គាល់ថា ព្រះយេស៊ូវគឺជាព្រះទេ។

ទីពីរ ការប្រើពាក្យ «ព្រះអម្ចាស់» គឺជាឋានន្តរដែលសំដែងនូវការគោរពនិងសេចក្ដីថ្លៃថ្នូរ។ នៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ម្ចាស់ទាសករ គឺជាមនុស្សម្នាក់ដែលមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ដើម្បីទិញទាសករ ត្រូវបានគេហៅថា «ម្ចាស់»។ ពាក្យនេះក៏ត្រូវបានគេប្រើសំរាប់ប្ដីនិងអ្នកគ្រប់គ្រងផងដែរ។

ទាសករត្រូវបានគេទិញ ហើយក្លាយទៅជាកម្មសិទ្ធិរបស់ម្ចាស់។ ព្រះគម្ពីរសញ្ញាថ្មីប្រើពាក្យនេះជាច្រើន ដើម្បីបង្ហាញនូវទំនាក់ទំនងរបស់យើងជាមួយព្រះគ្រីស្ទ។ ឧទាហរណ៍ លោកសាវកប៉ុលជាញឹកញាប់បានណែនាំខ្លួននៅក្នុងសំបុត្ររបស់លោក ដែលសរសេរទៅកាន់ពួកជំនុំដោយពាក្យថា «ប៉ុលខ្ញុំជាបាវបំរើរបស់ (doulos) របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ»។ គាត់រំលឹកគ្រីស្ទបរិស័ទថា ពួកគេមិនមែនជាម្ចាស់ខ្លួនឯងទៀតទេ ក៏ប៉ុន្តែពួកគេត្រូវបានទិញ ហើយនៅពេលនេះជាកម្មសិទ្ធិរបស់ព្រះអម្ចាស់របស់ពួកគេ គឺព្រះយេស៊ូវ។

ប៉ុន្តែទាំងនេះគឺជាអត្ថន័យកំរិតទាបនៃពាក្យថា«ម្ចាស់» (*Kurios*) នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ នៅពេលយើងទៅដល់កំរិតទីបី យើងនឹងចូលទៅដល់ ឋានន្តរកំពូលនៃសេចក្ដីថ្លៃថ្នូរ ការគោរព ហើយនឹង អំណាច។

*ឋានន្តរជាព្រះ*

ដើម្បីយល់នូវអត្ថន័យជាក់លាក់នៃឋានន្តរ «ព្រះអម្ចាស់» យើងត្រូវយល់ដឹងអំពីការប្រើពាក្យនេះនៅក្នុងព្រះគម្ពីរសញ្ញាចាស់និងនៅក្នុងសញ្ញាថ្មី។ ព្រះនាមបរិសុទ្ធរបស់ព្រះនៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺ «ព្រះយេហូវ៉ា» (នៅក្នុងព្រះគម្ពីរភាសាអង់គ្លេសភាគច្រើនប្រើ «Lord» ហើយព្រះគម្ពីរខ្មែរ គ.ខ.ប. បោះពុម្ពដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើ «ព្រះអម្ចាស់»)។ នៅក្នុងក្រិត្យវិន័យទាំងដប់ប្រការ ព្រះបានព្រមានអ៊ីស្រាអែលចំពោះការ

បំពាន ឬការប្រើព្រះនាមរបស់ព្រះខុស។ ជនជាតិយូដាបានប្រុងប្រយ័ត្នខ្លួនជានិច្ច ខ្លាចក្រែងពួកគេត្រូវបានជាប់ទោសពីការប្រមាថដល់ព្រះ។ ពួកគេបានបង្កើតឋានន្តរផ្សេងៗ ជំនួសអោយព្រះនាម «ព្រះយេហូវ៉ា»។ ឋានន្តរកំពូលគឺ «អាដូណាយ»ដែលមានន័យថា អង្គដែលមានអធិបតេយ្យភាពទាំងស្រុង។ ដូច្នេះ ឋានន្តរ «ព្រះអម្ចាស់» សំដៅទៅលើម្នាក់ដែលគ្រប់គ្រងលើប្រវត្តិសាស្ត្រ លើពិភពលោក និងជំនុំជំរះពិភពលោក។

ទំនុកដំកើង ១១០ ត្រូវបានអ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីដកស្រង់ ឬសរសេរប្រាប់ជាញឹកញាប់បំផុត។ ទំនុកដំកើង ១១០ ចាប់ផ្តើមសរសេរដោយ «ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដល់ព្រះអម្ចាស់នៃទូលបង្គំថា ចូរឲ្យឯងអង្គុយនៅខាងស្តាំអញ»។ ព្រះយេស៊ូវប្រើបទគម្ពីរនេះដើម្បីបង្ហាញថា នៅក្នុងពេលតែមួយ ទ្រង់គឺជាបុត្រារបស់ស្តេចដាវីឌផង ហើយជាព្រះអម្ចាស់នៃស្តេចដាវីឌផង (ម៉ាថាយ ២២:៤១-៤៦)។ បុត្រារបស់ស្តេចដាវីឌគឺជាព្រះអម្ចាស់(អាដូណាយ) របស់ស្តេចដាវីឌ។ គឺជាឋានន្តរកំពូលនោះហើយ ដែលស្មើទៅនឹង (អាដូណាយ) ដែលត្រូវបានប្រើសំរាប់ព្រះអង្គទ្រង់ផ្ទាល់ ហើយដែលត្រូវបានថ្វាយដល់ព្រះយេស៊ូវនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។

ភីលីព ២:៥-១១ បង្ហាញថា ឋានន្តរជាព្រះអម្ចាស់មានអត្ថន័យខ្ពស់បំផុត នៅពេលឋានន្តរនេះត្រូវបានប្រើសំរាប់ព្រះយេស៊ូវ។ គ្រប់ទាំងជង្គង់របស់មនុស្ស ទោះទាំងពួកស្តេច នឹងត្រូវលុតចុះនៅចំពោះព្រះគ្រីស្ទ ហើយប្រកាសប្រាប់ថា ព្រះគ្រីស្ទគឺព្រះអម្ចាស់។ ព្រះអង្គគឺជាព្រះអម្ចាស់លើគ្រប់ទាំងស្នាព្រះហស្ត។ ទ្រង់គឺព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។ ព្រះវរបិតារបស់ទ្រង់បានប្រទានគ្រប់ទាំងអំណាចមកឲ្យទ្រង់។ អំណាចជាព្រះអម្ចាស់របស់ព្រះយេស៊ូវនេះគឺជាមូលដ្ឋានគ្រឹះសំខាន់សំរាប់បេសកកម្មរបស់យើងក្នុងការបង្កើតសិស្សនៅគ្រប់ទាំងជាតិសាសន៍ (ម៉ាថាយ ២៨:១៨-២០; ទំនុកដំកើង ២:៧-១២)។ គោលបំណងនៃប្រវត្តិសាស្ត្រទាំងអស់របស់មនុស្ស គឺការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ ជាពេលដែលគ្រប់ទាំងជង្គង់នឹងត្រូវលុតចុះ ហើយគ្រប់ទាំងអណ្តាតត្រូវថ្លែងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់។

ការប្រើពាក្យ «ព្រះអម្ចាស់» (Kyrios) ខាងក្រៅព្រះគម្ពីរសញ្ញាថ្មីនៅសម័យសតវត្សទីមួយ។

ពាក្យ *Kyrios* «ព្រះអម្ចាស់» គឺមិនគ្រាន់តែជាពាក្យរបស់គ្រីស្ទបរិស័ទទេ។ សាសនាដទៃទៀតជាញឹកញាប់បានប្រើពាក្យ *Kyrios* ឬពាក្យឥត្ថីលិង្គ *Kyria* ដើម្បីសំដៅទៅលើព្រះប្រុសនិងព្រះស្រីផ្សេងៗ ដូចជា Isis Serapis ឬ Osiris។ ជាការសំខាន់ក្នុងការកត់សំគាល់ថា ព្រះចៅអធិរាជរ៉ូម ឈ្មោះថា សេសារ ក៏ត្រូវបានគេហៅថា «ព្រះអម្ចាស់» (Kyrios) ផងដែរ ដែលការនេះបាននាំអោយមានបញ្ហាដ៏ធំមួយ ដែលគ្រីស្ទបរិស័ទត្រូវតែប្រឈមនៅក្នុងសតវត្សទីមួយ។

*ការល្បងលភក្តីភាព*

វិបត្តិធំមួយដែលសហគមន៍គ្រីស្ទបរិស័ទដើមដំបូងបានជួបប្រទះទាក់ទងជាមួយទំនាក់ទំនងរបស់សហគមន៍គ្រីស្ទជាមួយអំណាចស៊ីវិល ជាពិសេសជាមួយនឹងរដ្ឋាភិបាលចក្រភពរ៉ូម។ គ្រីស្ទបរិស័ទ ជាច្រើនត្រូវបានសំឡាប់ដោយការបៀតបៀនរបស់អធិរាជនេរ៉ូនិងអធិរាជក្រោយៗមកទៀតរបស់ច្រកភពរ៉ូម។

ការសំឡាប់គ្រីស្ទបរិស័ទដ៏ព្រៃផ្សៃនេះមានរយៈពេលពីរបីសតវត្ស។ តាមបញ្ជារបស់អធិរាជនេរ៉ូ គ្រីស្ទបរិស័ទត្រូវបានគរជាគំនរហើយបន្ទាប់មកដុត ដើម្បីធ្វើជាចន្លុះមនុស្សដើម្បីបំភ្លឺដល់សួនច្បាររបស់អធិរាជនេរ៉ូនៅពេលយប់។ គ្រីស្ទបរិស័ទដទៃទៀតត្រូវបានបោះទៅឲ្យសត្វតោស៊ី។ ការនេះបានកើតឡើងដោយសារតែប្រជាពលរដ្ឋគ្រប់រូបនៅក្នុងចក្រភពរ៉ូមត្រូវតែនិយាយថា សេសារគឺជា «ព្រះអម្ចាស់ »។ ការឆ្លើយតបរបស់គ្រីស្ទបរិស័ទគឺ «យើងនឹងគោរពដល់អ្នកកាន់អំណាចរដ្ឋបាលស៊ីវិល យើងនឹងជូនទ្រព្យសម្បត្តិ១ភាគដប់និងសួយសាអាកររបស់យើងដល់អធិរាជសេសារ។ យើងនឹងធ្វើជាប្រជាពលរដ្ឋល្អរបស់ចក្រភពរ៉ូម ប៉ុន្តែយើងមិនអាចនិយាយបានថា សេសារ គឺជា «ព្រះអម្ចាស់»បានទេ ពីព្រោះព្រះអម្ចាស់របស់យើងគឺជាព្រះគ្រីស្ទ ហើយព្រះគ្រីស្ទគឺជាព្រះអម្ចាស់។

អភិបាលក្នុងក្រុងស្មឺនា Smyrna ឈ្មោះថា ប៉ូលីខាប Polycarp អាយុ៨៦ឆ្នាំ ត្រូវបានចោទប្រកាន់អំពីអំពើក្បត់ជាតិ ដោយសារតែគាត់បានបដិសេធមិនសូត្រសម្បថដល់អធិរាជសេសារ។ រដ្ឋចក្រភពរ៉ូមមិនចង់ធ្វើឲ្យគាត់មានគ្រោះថ្នាក់នោះទេ។ គាត់មានការគោរពពីអ្នកដទៃ ហើយមានទំនាក់ទំនងល្អជាមួយនឹងអាជ្ញាធរ។

លោក ប៉ូលីខាបត្រូវបានគេនាំមកកាន់វេទិកា ចំពោះមុខអ្នកទស្សនារាប់ពាន់នាក់ ប៉ុន្តែរហូតមកដល់ពេលវេលាចុងក្រោយ មន្ត្រីរដ្ឋាភិបាលចង់ឲ្យគាត់រួចពីការកាត់ទោសប្រហារជីវិត។ ពួកគេបានផ្ដល់ឲ្យគាត់នូវឱកាសចុងក្រោយ។ លោក ប៉ូលីខាប គ្រាន់តែត្រូវនិយាយថា អធិរាជ «សេសារគឺជាព្រះម្ចាស់ » ហើយបន្ទាប់មកពួកគេនឹងមិនប្រហារជីវិតគាត់ទេ។ ប៉ុន្តែ លោក ប៉ូលីខាបបានមានប្រសាសន៍ថា «ខ្ញុំបានស្មោះត្រង់ជាមួយនឹងព្រះអម្ចាស់របស់ខ្ញុំអស់រយៈពេល៨៦ ឆ្នាំមកហើយ ហើយទ្រង់បានមានសេចក្ដីមេត្តាករុណានិងព្រះគុណមកដល់ខ្ញុំអស់រយៈពេល៨៦ឆ្នាំមកហើយដែរ។ នៅពេលនេះ តើឲ្យខ្ញុំអាចបដិសេធទ្រង់បានយ៉ាងម៉េចកើត?» បន្ទាប់មក គាត់ត្រូវបានគេកាត់ទោសប្រហារជីវិតទៅ។

*ការអនុវត្តន៍នៅក្នុងប្រទេសកម្ពុជា*

គ្រីស្ទបរិស័ទខ្មែរក៏ប្រើពាក្យ «ព្រះអម្ចាស់» នេះសំរាប់ព្រះយេស៊ូវ ដែលជាពាក្យដែលប្រជាជនខ្មែរប្រើសំរាប់អ្នកមានយសស័ក្តិខ្ពស់ដទៃទៀតផងដែរ។ ទង្វើនេះគួរទទួលយកបាន ពីព្រោះយើងឃើញថា អ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីបានប្រើពាក្យភាសាក្រិក *Kyrios* (ដែលមានន័យថា ម្ចាស់) ដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងសង្គមរួចទៅហើយ សំរាប់មនុស្សលំដាប់ខ្ពស់នៅក្នុងសង្គម ហើយនិងសំរាប់ព្រះផ្សេងៗផងដែរ។  ទោះយ៉ាងណា គ្រីស្ទបរិស័ទនៅតែយល់ឃើញថា នៅពេលយើងនិយាយថា ព្រះយេស៊ូវគឺជាព្រះ

អម្ចាស់ គឺយើងកំពុងតែសំដៅទៅលើអត្ថន័យជ្រៅបំផុត គឺទ្រង់គឺជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ហើយទ្រង់ខ្ពស់លើទាំងអស់។ នៅពេលមនុស្សណាម្នាក់ ឬព្រះដទៃណាមួយអះអាងកំរិតបែបនេះ យើងមិនអាចទទួលយកការអះអាងនោះបានទេ ដូចជាគ្រីស្ទបរិស័ទនៅសតវត្សទីមួយមិនអាចទទួលយកការអះអាងរបស់អធិរាជរ៉ូម ថា គាត់គឺជា ព្រះអម្ចាស់ដែលខ្ពស់បំផុតនោះ។ យើងអាចមានការបៀតបៀនដោយសារនេះ ប៉ុន្តែនេះគឺផ្នែកមួយនៃសេចក្តីស្មោះត្រង់របស់យើងចំពោះព្រះគ្រីស្ទ ខណៈដែលយើងកំពុងទន្ទឹងរង់ចាំដល់ថ្ងៃដែលគ្រប់ទាំងជង្គង់នឹងត្រូវលុតចុះ ហើយគ្រប់ទាំងអណ្តាតប្រកាសថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអម្ចាស់។

**Bibliography**


Ellenburg, D. (2003). Lord. In (C. Brand, C. Draper, A. England, S. Bond, E. R. Clendenen, & T. C. Butler, Eds.)*Holman Illustrated Bible Dictionary*. Nashville, TN: Holman Bible Publishers.

Elwell, W. A., & Beitzel, B. J. (1988). In *Baker encyclopedia of the Bible*. Grand Rapids, MI: Baker Book House.

Sproul, R. C. (2005). *The Unexpected Jesus: The Truth Behind His Biblical Names*. Fearn, UK: Christian Focus Publications.

Witherington, B. I. (1992). Lord. In (J. B. Green & S. McKnight, Eds.) *Dictionary of Jesus and the Gospels*. Downers Grove, IL: InterVarsity Press.